ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៧០ អយក.ជសក

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/០៩៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- តាមស្មារតីនៃកិច្ចប្រជុំថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៤ ដើម្បីបង្កើតក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា សរសេរជាអក្សរកាត់ថា "ក.ស.ក." ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍនិងពង្រឹងគុណភាពអប់រំគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនៅកម្ពុជា។

**ប្រការ ២.-**

សមាសភាពនៃក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា មានសមាសភាពដូចខាងក្រោម៖



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

| | | | | |
|---|---|---|---|---|
| ឯកឧត្តម | **អ៊ុម** | **រម្យណី** | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ប្រធាន |
| ឯកឧត្តម | **ដេត** | **ជាលី** | សាកលវិទ្យាធិការនៃ ស.ភ.ភ.ព | អនុប្រធាន |
| ឯកឧត្តម | **ហោ** | **ម៉េង** | សាកលវិទ្យាធិការនៃ ស.ជ.គ. | សមាជិក |
| ឯកឧត្តម | **លុយ** | **ចណ្ណា** | សាកលវិទ្យាធិការនៃ ស.ភ.ន.វ.ស. | សមាជិក |
| ឯកឧត្តម | **សាផុន** | **វឌ្ឍនៈ** | សាកលវិទ្យាធិការនៃ ស.វ.ស. | សមាជិក |
| ឯកឧត្តម | **ម៉ៅ** | **ប៊ុនថាន** | សាកលវិទ្យាធិការនៃ ស.វ.ភ.ក. | សមាជិក |
| ឯកឧត្តម | **បុង** | **សុវត្ថិ** | សាកលវិទ្យាធិការនៃ ស.ភ.វ.ស. | សមាជិក |
| ឯកឧត្តម | **ទុំ** | **សារាវុធ** | សាកលវិទ្យាធិការនៃ ស.ស.រ. | សមាជិក |
| ឯកឧត្តម | **អ៊ុក** | **ថូន** | សាកលវិទ្យាធិការនៃ ស.ជ.ស.ក. | សមាជិក |
| ឯកឧត្តម | **សំ** | **ម៉ា** | សាកលវិទ្យាធិការនៃ ស.ម.ជ. | សមាជិក |
| ឯកឧត្តម | **សៀង** | **សុវណ្ណា** | នាយកវិទ្យាស្ថានជាតិអប់រំ | សមាជិក |
| លោកជំទាវ | **សៀង** | **ឯមទទឹម** | សាកលវិទ្យាធិការនៃ ស.ប.ជ. | សមាជិក |
| លោក | **ភុល** | **នរិទ្ធ** | នាយករងនៃ វ.ប.ក. អគ្គលេខាធិការនិងជាអគ្គហិរញ្ញឹក | |

សមាសភាពក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជានេះ មានអាណត្តិ២ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើសេចក្តីសម្រេចនេះ។

**ប្រការ ៣.-**

ក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា មានតួនាទីនិងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- លើកកម្ពស់គុណភាពអប់រំឧត្តមសិក្សាស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- ជួយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែលនៅទន់ខ្សោយ
- លើកកម្ពស់គុណភាព ផ្លាស់ប្តូរបទពិសោធការងារស្រាវជ្រាវវិទ្យាសាស្ត្រ និងការបោះពុម្ពផ្សាយអត្ថបទបច្ចេកទេស
- សហការតម្រង់ទិស បណ្តុះបណ្តាលធនធានមនុស្សកម្រិតឧត្តមសិក្សាឱ្យស្របតាមតម្រូវការទីផ្សារការងារ
- ពិភាក្សានិងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាក្នុងដំណើរការរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ
- សិក្សាអំពីវឌ្ឍភាពនៃការអប់រំរបស់គ្រឹះស្ថានឧត្តមសិក្សានៅក្រៅប្រទេសដើម្បីអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា
- រៀបចំសិក្ខាសាលា ឬសន្និសីទវិទ្យាស្ត្រថ្នាក់ជាតិ អន្តរជាតិ
- ស្វែងរកជំនួយបច្ចេកទេសពីដៃគូនានាដើម្បីគាំទ្រការងារអប់រំនៅថ្នាក់ឧត្តមសិក្សា និងសិក្សាបច្ចេកទេស
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងទៀតដែលក្រសួងអប់រំ យុវជន និងកីឡាប្រគល់ជូន។

**ប្រការ ៤.-**

ក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជាមានលេខាធិការដ្ឋាននៅក្នុងសាកលវិទ្យាល័យឬវិទ្យាស្ថានដែលសាកលវិទ្យាធិការឬនាយកត្រូវបានជ្រើសតាំងជាប្រធាន។

ប្រធានក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា អាចស្នើសុំមន្ត្រីពីគ្រឹះស្ថានឧត្តមសិក្សាសាធារណៈពាក់ព័ន្ធ ដើម្បីបម្រើការងារនៅក្នុងលេខាធិការដ្ឋាន។

**ប្រការ ៥.-**

ក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជាមានសិទ្ធិប្រើប្រាស់ត្រារបស់សាកលវិទ្យាល័យឬវិទ្យាស្ថានដែលសាកលវិទ្យាធិការឬនាយកត្រូវបានជ្រើសតាំងជាប្រធាន ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ ៦.-**

យន្តការនិងនីតិវិធីនៃការបំពេញការងារ ការកំណត់បែបបទផ្សេងៗ និងការលើកទឹកចិត្តនានានៅក្នុងក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជានិងលេខាធិការដ្ឋានត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**ប្រការ ៧.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ និងសាមីខ្លួន ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ០៣ ឆ្នាំ២០១៥

**កន្លែងទទួល៖**

- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ នា.នីតិកម្ម

បណ្ឌិត ហង់ ជួន ណារ៉ុន